# ដំណើរផ្សងព្រេងមួយថ្ងៃ
# ក្នុងពិភពគណិតវិទ្យាដ៏អស្ចារ្យ

# A Day's Adventure in Math Wonderland



Jin Akiyama • Mari-Jo Ruiz

Illustrations by Frances Alcaraz

World Scientific

# ដំណើរផ្សងព្រេងមួយថ្ងៃក្នុងពិភពគណិតវិទ្យាដ៏អស្ចារ្យ

Jin Akiyama

Tokai University, Japan

Mari-Jo Ruiz

Ateneo de Manila University, Philippines

Illustrations by Frances Alcaraz

World Scienticfic

NEW JERSEY. LONDON. SINGAPORE. BEJING. SHANGHAI. HONG KONG. TAIPEI. CHENNAI

ជំពូកទី១



តើសិក្សាគណិតវិទ្យាពិតជាសប្បាយរីករាយមែនឬ ?



ជួងបានផ្តល់សញ្ញាឱ្យដឹងថាដល់ពេលត្រូវឈប់សម្រាកពីការសិក្សា។ក្មេងៗប្រញាប់ប្រញាល់រត់ទៅកាន់ទីធ្លាកំសាន្ត។ Ichiro សម្លឹងមើលជុំវិញខ្លួនដើម្បីរកមិត្តភ័ក្តិរបស់ វាគឺ Jai និង Kino ។ Ichiro ឃើញពួកគេនៅជាមួយក្មេងមួយក្រុមដែលនៅឈរផ្តុំជុំវិញ Kentaro ។

ពួកគេហាក់បីដូចជាស្លុងនឹងអ្វីដែល Kentaro កំពុងនិយាយ។ Ichiro បានបន្លឺសម្លេងពីចម្ងាយ "ខ្ញុំឆ្ងល់ណាស់ថាអ្វីដែល Kentaro កំពុងនិយាយពិតជាគួរឱ្យចាប់អារម្មណ៍មែនឬ?"



Kentaro និយាយបន្តដោយជង្ហក់ "វាគឺជារឿងគួរឱ្យសប្បាយរីករាយមែន ព្រោះខ្ញុំបានជិះលើត្រីចក្រក្រយានមួយដែលមានកង់រាងជាការេ... ខ្ញុំរត់ចុះតាមកាំជណ្ដើតន្ត្រីមួយហើយខ្ញុំបានឈ្នះការប្រកួតមួយដោយសារតែជិះក្ដារបន្ទះមានភាពរអិលខ្លាំង...។"

Ichiro សួរ "តើ Kentaro បានទៅទីណា?"

Kino ឆ្លើយ "ពិភពគណិតវិទ្យាដ៏អស្ចារ្យ (Math Wonderland)"

Ichiro និយាយ "អូ! កន្លែងហ្នឹងទៀតហើយ"។

Jai ឆ្ងល់ "តើឯងចង់និយាយពីអ្វី?"

Ichiroឆ្លើយថា"លោកយាយរបស់ខ្ញុំនិយាយមិនឈប់សោះអំពីកន្លែងនោះពេលបរិភោគអាហារពេលព្រឹក។ គាត់បានឃើញកម្មវិធីក្នុងទូរទស្សន៍ ហើយនិយាយថា ក្មេងៗហាក់បីដូចជាកំពុងលេងកំសាន្តជាមួយនឹងគំរូគណិតវិទ្យា"។ គាត់បន្ថែមទៀតថា "ខ្ញុំមិនអាចស្រមៃឃើញនូវអ្វីដែលគួរឱ្យសប្បាយរីករាយជាមួយនឹងគំរូគណិតវិទ្យានោះទេ"។

Jai តបវិញ "គណិតវិទ្យាគឺល្អតើ!"

Ichiro រៀនបានយ៉ាងពូកែនៅឯសាលារៀនដោយមិនចាំបាច់ប្រឹងប្រែងខ្លាំងឡើយ ប៉ុន្តែគណិតវិទ្យាមិនបានធ្វើឱ្យគាត់មានការចាប់អារម្មណ៍នោះទេ ។ គាត់យល់ថាថ្នាក់រៀនគណិតវិទ្យា របស់គាត់គឺគួរឱ្យធុញថប់ខ្លាំងណាស់។ ពេលខ្លះគាត់អង្គុយងក់ក្នុងថ្នាក់រៀន។ ជាងនេះទៅទៀតលំហាត់គណិតវិទ្យាដែលត្រូវធ្វើនៅផ្ទះ បានធ្វើឱ្យគាត់ឃ្លាតឆ្ងាយពីល្បែងក្នុងកុំព្យូទ័រ ការមើលទូរទស្សន៍ និងសកម្មភាពជាទីពេញចិត្តរបស់គាត់ដូចជាការដោះតុក្កតាយន្តហើយតម្រៀបឡើងវិញ។

Kino ដែលជាក្មេងធ្វើអ្វីតាមអំពើចិត្តបានប៉ះស្មា Ichiro ហើយនិយាយថាតោះយើងទៅទីនោះនៅចុងសប្តាហ៍នេះ។

Jai និយាយ "ខ្ញុំក៏ចង់ទៅមើលវាដែរ"។

Ichiro មិនបានរៀបចំគម្រោងទៅណាទេនៅចុងសប្តាហ៍នេះ ប៉ុន្តែដោយសារមិត្តល្អរបស់គាត់បបួល បានធ្វើឱ្យដំណើរកំសាន្តនេះប្រែក្លាយទៅជាដំណើរផ្សងព្រេងមួយ។




ចុងសប្តាហ៍មកដល់ Ichiro Jai និង Kino បានជិះរថយន្តក្រុងធ្វើដំណើរទៅកាន់គោលដៅដែលបានគ្រោងទុក មិនយូរប៉ុន្មានពួកគេបានទៅដល់ ហើយឈរនៅពីមុខអាគារធម្មតាមួយមានកម្ពស់ពីរជាន់។

Kino សួរ "តើយើងមកត្រូវចំកន្លែងហើយឬ?" គាត់ទៅដល់ទ្វារមុនគេ ហើយ Ichiro និង Jai ដើរពីក្រោយ។ គេទាំងអស់គ្នាឃើញស្លាកលើសរសេរថា:

"MATH WONDERLAND" ពិភពគណិតវិទ្យាដ៏អស្ចារ្យ

ពួកគេបានរុញទ្វារសន្សឹមៗ និងឆ្ងល់ថា តើការដើរកំសាន្តនេះពិតជាការចំណាយពេលវេលាឥតប្រយោជន៍ឬមួយយ៉ាងណា? ភ្លាមៗនោះបន្ទាប់ពីពួកគេចូលទៅដល់ខាងក្នុងពួកគេបានឮសម្លេងកងរំពងពីក្មេងៗ ជាច្រើន។